**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
លេខ : ១៤៧ អ.ជ.ប.ជ.អ

# សេចក្តីសម្រេចចិត្ត
# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# លើកទី១ ឆ្នាំ២០១៩ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៩ បានដំណើរការរយៈពេលមួយព្រឹកពេញ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ នៅសណ្ឋាគារសង្គហមិត្តគយ ខេត្តកែប ដោយមានការចូលរួមពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមការងារ លេខាធិការដ្ឋាន ក្រសួង ស្ថាប័ន ចំនួន៣០ រាជធានី ខេត្តទាំង២៥ អង្គការ និងសង្គមស៊ីវិល ចំនួន៩ សរុបចំនួន១៦៨រូប។

អង្គប្រជុំទាំងមូល បានធ្វើការគោរពថ្លែងនូវអំណរគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ ដាក់ចេញនូវវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ តាមរយៈសេចក្តីជូនដំណឹងលេខ២១៣សជណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់នូវការជំរុញលើកទឹកចិត្តកាន់តែខ្លាំងក្លាបន្ថែមទៀត ដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការបំពេញការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

អង្គប្រជុំក៏បានធ្វើការថ្លែងអំណរគុណ និងកោតសរសើរផងដែរចំពោះសមាជិក សមាជិកានៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៨ ដែលបានលើកគំនិតប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរៀបចំឱ្យមានសេចក្តីសម្រេចចិត្តដ៏ល្អមួយ នាំដល់ការស្នើសុំរាជរដ្ឋាភិបាលសម្រេចចេញនូវវិធានការខាងលើ។

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក សមាជិក សមាជិកាទាំងអស់ បានប្តេជ្ញាបន្តនូវឆន្ទៈរួមគ្នា ដោយទទួលខុសត្រូវខ្ពស់ក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាល

អាសយដ្ឋាន : អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ទូរស័ព្ទ (855) 023 882 241 និង ទូរសារ (855)123 885 129
Tel: (855) 23 882 241 Fex: (855) 23 885 129 E-mail: info@naaa.gov.kh Website: naaa.gov.kh

ជាលមេរោគអេដស៍ឱ្យបានជោគជ័យ តាមរយៈការធ្វើឱ្យសម្រេចនូវគោលនយោបាយសូន្យបី "សូន្យនៃការឆ្លងមេរោគអេដស៍ថ្មី សូន្យនៃការមាក់ងាយនិងរើសអើង និងសូន្យនៃការស្លាប់ដោយសារជំងឺអេដស៍ដោយមិនបានទទួលការព្យាបាល" និងគោលដៅយុទ្ធសាស្ត្រ ៩៥-៩៥-៩៥ តាមកាលកំណត់នៅឆ្នាំ ២០២៥-២០៣០ (៩៥% នៃអ្នកដែលផ្ទុកមេរោគអេដស៍ទាំងអស់បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ពួកគេ ៩៥% នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានធ្វើរោគវិនិច្ឆ័យហើយ បានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ និង៩៥%នៃអ្នកទាំងអស់ដែលទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍នៅក្នុងខ្លួន ដែលលែងជាគ្រោះគំរាមកំហែងដល់អ្នកផ្ទុកមេរោគអេដស៍)។

នៅក្នុងគោលបំណងសម្រេចនូវឆន្ទៈខាងលើ កិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដាក់ចេញនូវការសម្រេចចិត្តដូចតទៅ ៖

១. ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងវិធានការទាំង៦ដែលបានកំណត់ក្នុងកិច្ចប្រជុំអន្តរក្រសួងកាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា បន្តធ្វើការតាមដានត្រួតពិនិត្យ វាយតម្លៃវឌ្ឍនភាពនៃវិធានការដែលបានកំណត់ ដើម្បីឱ្យតំណាងក្រសួងស្ថាប័នទាំងនោះ អាចនាំយករបាយការណ៍មកជម្រាបជូនកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៩ខាងមុខ។

២. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តទាក់ទងជាមួយវិស័យឯកជន និងសប្បុរសជននានា ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងការចូលរួមរបស់វិស័យឯកជន និងសប្បុរសជនក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ថ្ងៃពុធ ៣កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅខេត្តកែប ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩

**ប្រធានអង្គប្រជុំ**

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**